# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងតាមស្មារតីអង្គប្រជុំលើកទី ១៩ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ :**

អនុលោមតាមមាត្រា ៧៧ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កំរិតនៃការផ្ទេរពីចំណូលចរន្តនៃថវិការដ្ឋទៅក្នុងគណនីមូលនិធិឃុំ សង្កាត់ មានដូចខាងក្រោម :

- ឆ្នាំថវិកា ២០០៥ : ២.៥២ ភាគរយ នៃចំណូលចរន្តរបស់ថវិការដ្ឋ

- ឆ្នាំថវិកា ២០០៦ : ២.៥៤ ភាគរយ នៃចំណូលចរន្តរបស់ថវិការដ្ឋ
- ឆ្នាំថវិកា ២០០៧ : ២.៥៦ ភាគរយ នៃចំណូលចរន្តរបស់ថវិការដ្ឋ

**មាត្រា ២ :**

ការផ្ទេរថវិការដ្ឋប្រចាំឆ្នាំទៅក្នុងគណនីមូលនិធិឃុំ សង្កាត់ និងការផ្ទេរពីគណនីមូលនិធិឃុំ សង្កាត់ទៅគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នីមួយៗ ត្រូវអនុវត្តជាបណ្ដើរៗ ដោយផ្អែកលើលទ្ធភាពនៃការប្រមូលចំណូលថវិការដ្ឋ និងកំណត់ដូចខាងក្រោម :

- យ៉ាងតិច ៥០ភាគរយ នៃចំនួនផ្ទេរសរុប រហូតដល់ថ្ងៃទី ៣១ ខែ ឧសភា
- យ៉ាងតិច ៨០ភាគរយ នៃចំនួនផ្ទេរសរុប រហូតដល់ថ្ងៃទី ៣១ ខែ សីហា
- និង ១០០ភាគរយ នៃចំនួនផ្ទេរសរុប រហូតដល់ថ្ងៃទី ៣១ ខែ តុលា

**មាត្រា ៣ :**

ឃុំ សង្កាត់ទាំងអស់ ត្រូវទទួលបានធនធានមូលនិធិសំរាប់រដ្ឋបាលទូទៅ និងសំរាប់អភិវឌ្ឍន៍ ។

ធនធានមូលនិធិដែលផ្ដល់សំរាប់សមាសភាគរដ្ឋបាលទូទៅ មិនត្រូវច្រើនជាង ១/៣ ( មួយភាគបី ) នៃធនធានមូលនិធិសរុប ។

ធនធានមូលនិធិដែលផ្ដល់សំរាប់សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន មិនត្រូវតិចជាង ២/៣ ( ពីរភាគបី ) នៃធនធានមូលនិធិសរុប ។

**មាត្រា ៤ :**

ធនធាននៃសមាសភាគរដ្ឋបាលទូទៅ ត្រូវបានប្រើប្រាស់សំរាប់ការចំណាយទាំងឡាយ ដូចបានចែងក្នុងកថាខ័ណ្ឌទី ២ មាត្រា ១៥ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្ដីពីមូលនិធិឃុំ សង្កាត់ និងសំរាប់ចំណាយឧបត្ថម្ភដល់មន្ត្រីភូមិ តាមរបបកំណត់ជាធរមាន ។

ធនធាននៃសមាសភាគរដ្ឋបាលទូទៅរួមមាន ចំណាយសំរាប់ប្រតិបត្តិការរដ្ឋបាល ចំណាយសំរាប់ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងចំណាយសំរាប់ឧបត្ថម្ភមន្ត្រីភូមិ ។

ចំណាយសំរាប់ប្រតិបត្តិការរដ្ឋបាល ត្រូវបានគណនាដោយយកសរុបធនធាននៃសមាសភាគរដ្ឋបាលទូទៅ ដកចេញនូវចំណាយសំរាប់ប្រាក់បំណាច់ក្រុមប្រឹក្សាឃុំ សង្កាត់ និងចំណាយសំរាប់ឧបត្ថម្ភមន្ត្រីភូមិ រួចទើបធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥ :**

ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានប្រើប្រាស់សំរាប់ការចំណាយទាំងឡាយ ដូចបានចែងក្នុងកថាខ័ណ្ឌទី ៣ មាត្រា ១៥ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្ដីពីមូលនិធិឃុំ សង្កាត់ និងត្រូវបានវិភាជន៍ទៅអោយឃុំ សង្កាត់នីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម :

- ចំណែកស្មើគ្នាជាមូលដ្ឋាន
- ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ ( ឯកសាររបស់ក្រសួងផែនការ )
- សន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ ( ឯកសាររបស់ក្រសួងផែនការ )
- សន្ទស្សន៍ផ្សេងៗទៀត តាមការកំណត់របស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់

សមាមាត្រនៃមូលនិធិសំរាប់អភិវឌ្ឍន៍មូលដ្ឋាន សំរាប់សន្ទស្សន៍នីមួយៗខាងលើនេះ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ។

**មាត្រា ៦ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ស ខេង** **នរោត្តម សិរីវុឌ្ឍ**

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**គាត ឈន់**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ